# អារម្ភកថា

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-០៥ បង្ហាញពីដំណាក់កាលការងារសំខាន់មួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើកំណែទំរង់សេវាអប់រំកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់។ អស់រយៈពេលពីរ-បីឆ្នាំនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមកនេះ ក្រសួងនិងដៃគូអភិវឌ្ឍន៍របស់ខ្លួនបានធ្វើឱ្យមានការកែលំអយ៉ាងច្រើនក្នុងការផ្តល់ឱកាសអប់រំប្រកបដោយសមធម៌ ការកែលំអស្តង់ដាគុណភាព និងការគ្រប់គ្រងសេវាអប់រំ។ ទន្ទឹមនឹងនេះ យើងក៏ទទួលបាននូវបទពិសោធន៍ជាច្រើន ដើម្បីកែលំអសេវាអប់រំនៅថ្ងៃអនាគត។

ក្រៅពីការរីកចំរើននេះ ក្រសួងទទួលស្គាល់ថា ដំណើរការកែទំរង់វិស័យអប់រំត្រូវតែបង្កើនល្បឿនដើម្បីឱ្យការចូលរៀនបានច្រើន និងលើកកំពស់គុណភាពអប់រំដល់កុមារា កុមារី យុវជន និងយុវតីកម្ពុជា។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ គឺជាជំហានកសាងផែនការដ៏មានសារៈសំខាន់សំរាប់ដំណាក់កាលបន្ទាប់នៃគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទំរង់វិស័យអប់រំ។ ឯកសារនេះ គឺជាការសំយោគនៃឯកសារយុទ្ធសាស្ត្រជាច្រើនដែលបានរៀបចំដោយមន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជននិងកីឡា និងទីប្រឹក្សាអន្តរជាតិទាំងឡាយ។ យើងមានទំនុកចិត្តយ៉ាងមុតមាំថា ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ នឹងផ្តល់មាគ៌ាដ៏ត្រឹមត្រូវ និងជាកម្លាំងរុញច្រានដ៏ចាំបាច់សំរាប់ការអភិវឌ្ឍវិស័យអប់រំអោយបានលឿនទៅមុខ និងមានប្រសិទ្ធភាពដែលជាប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់រូប ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ ត្រូវបានរៀបរៀងឡើង ដើម្បីកំណត់ដំណាក់កាលនិងកម្មវិធីរំកិលនៃគោលនយោបាយអប់រំជាអាទិភាព និងយុទ្ធសាស្ត្រកំណែទំរង់រយៈពេល៥ឆ្នាំខាងមុខ។ នៅក្នុងដំណាក់កាលនៃដំណើរការកែទំរង់នេះ អាទិភាពខ្ពស់របស់ក្រសួង គឺការចូលរៀនប្រកបដោយសមធម៌ និងមានគុណភាពខ្ពស់ក្នុងការអប់រំមូលដ្ឋាន ដែលជាយុទ្ធសាស្ត្រនិងចំណុចដៅផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៤-០៨ ក៏សង្កត់ធ្ងន់ផងដែរលើការពង្រីកការងារអប់រំក្រៅប្រព័ន្ធនិងការបណ្តុះបណ្តាលជំនាញដល់យុវជន ការពង្រីកឱកាសអប់រំនៅមធ្យមសិក្សាទុតិយភូមិ និងក្រោយមធ្យមសិក្សា តាមរយៈការកសាងភាពជាដៃគូឱ្យបានល្អរវាងរាជរដ្ឋាភិបាល មាតាបិតាសិស្ស សហគមន៍ និងវិស័យឯកជន ។

ដំណាក់កាលបន្ទាប់នៃកំណែទំរង់វិស័យអប់រំ នឹងត្រូវពង្រីកឱ្យកាន់តែស៊ីជំរៅថែមទៀតលើយុទ្ធសាស្ត្រជួយដល់ជនក្រីក្រ សំដៅកាត់បន្ថយឧបសគ្គនានារារាំងដល់ឱកាសទទួលការអប់រំរបស់ពួកគេ ហើយធានាថាសេវាអប់រំដែលមានគុណភាពខ្ពស់ពិតជាបានទៅដល់តំបន់ដាច់ស្រយាល តំបន់ព្រំដែន និងតំបន់ជួបការលំបាកនានា ដែលនោះគឺជាប្រធានបទដ៏សំខាន់មួយទៀតរបស់យើងទាំងអស់គ្នា។ វត្ថុបំណងនៃកំណែទំរង់វិស័យអប់រំមួយ

ទៀត គឺត្រូវធានាថាការចំណាយលើវិស័យអប់រំពិតជាទទួលបាននូវផលប៉ះពាល់ជាអតិបរមា ហើយទន្ទឹមនោះ ក៏ត្រូវរៀបចំអោយមានវិធានការច្បាស់លាស់ ដើម្បីធានាប្រសិទ្ធភាពនៃការចំណាយថវិកាអប់រំ។ ការធានាអោយបាននូវការលើកទឹកចិត្ត និងការបណ្តុះបណ្តាលមន្ត្រីអប់រំអោយមានជំនាញច្បាស់លាស់ គឺជាសមាសភាគដ៏សំខាន់នៃកំណែទំរង់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ការពង្រឹងប្រព័ន្ធច្បាប់អប់រំ អភិបាលកិច្ចល្អ និងការទទួលខុសត្រូវខ្ពស់ ក៏ជាកិច្ចការមួយដែលត្រូវយកចិត្តទុកដាក់អោយបានខ្លាំងក្លាក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ។ យុទ្ធសាស្ត្រសំខាន់ គឺការបង្កើនសមាហរណកម្មអោយបានពេញលេញរវាងការងារអប់រំ យុវជន អប់រំកាយ និងកីឡា អោយទៅជាផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ។

ជាទីបញ្ចប់ ក្រសួងអប់រំ យុវជន និងកីឡា សូមសំដែងនូវអំណរគុណដ៏ស្មោះស្ម័គ្រ ចំពោះមន្ត្រីរាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជននិងកីឡា អ្នកបច្ចេកទេស ដែលមានការពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកយ៉ាងធំធេងក្នុងការកសាងផែនការនេះ។

**បណ្ឌិត កុល ផេង**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# ពាក្យសរសេរកាត់

# Abbreviations

| អក្សរកាត់ | ពាក្យពេញជាភាសាអង់គ្លេស | ពាក្យពេញជាភាសាខ្មែរ |
|---|---|---|
| AIDS | Acquired Immune Deficiency Syndrome | ជំងឺអេដស៍ |
| BMC | Budget Management Centre | អង្គភាពគ្រប់គ្រងថវិកា |
| CAR | Council for Administrative Reform | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| CBCG | Capacity Building Coordination Group | ក្រុមសំរបសំរួលការកសាងសមត្ថភាព |
| CG | Consultative group | ក្រុមពិគ្រោះយោបល់ |
| CLLC | Community Lifelong Learning Centre | មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| CDP | Cambodia Development Plan | ផែនការអភិវឌ្ឍន៍កម្ពុជា |
| DG | Director General | អគ្គនាយក |
| DGAF | Directorate General of Administrative and Finance | អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| DGE | Directorate General of Education | អគ្គនាយកដ្ឋានអប់រំ |
| DGHE/TVET | Directorate General of Higher Education and TVET | អគ្គនាយកដ្ឋានឧត្តមសិក្សា និង អប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ |
| ECCD | Early Childhood Care and Development | ការអភិវឌ្ឍ និងគាំពារកុមារតូច |
| EFA | Education For All | ការអប់រំសំរាប់ទាំងអស់គ្នា |
| EFMC | Education Finance Management Committee | គណៈកម្មាធិការគ្រប់គ្រងហិរញ្ញវត្ថុអប់រំ |
| EMIS | Education Management Information System | ប្រព័ន្ធពតិមានគ្រប់គ្រងអប់រំ |
| ESP | Education Strategy Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| ESSP | Education Sector Support Program | កម្មវិធីគាំទ្រវិស័យអប់រំ |
| ESWG | Education Sector Working Group | ក្រុមការងារវិស័យអប់រំ |
| FTI | Fast-Track Initiative | ការផ្តួចផ្តើមធ្វើអោយសំរេចការអប់រំបានឆាប់ |
| HEI | Higher Education Institutions | គ្រឹះស្ថានឧត្តមសិក្សា |
| HIV | Human Immunodeficiency Virus | មេរោគហ៊ីវ |
| HQ | Headquarters of MoEYS | ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា |
| ICT | Information Communication Technology | បច្ចេកវិទ្យាពតិមាន និង ការប្រាស្រ័យទាក់ទង |
| IEC | Information, Education, Communication | ពតិមាន ការអប់រំ ការប្រាស្រ័យទាក់ទង |

| | | |
|---|---|---|
| IFAPER | Integrated Fiduciary Assessment Public Expenditure Review | ការពិនិត្យឡើងវិញការចំណាយសាធារណៈ<br>និងការវាយតំលៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ |
| IGE | Inspectorate General | អគ្គាធិការដ្ឋាន |
| INSET | In-Service Training | ការធ្វើវិក្រឹត្យការ |
| MDG | Millennium Development Goals | គោលដៅអភិវឌ្ឍន៏សហសវត្ស |
| MoEF | Ministry of Education and Finance | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| MoEYS | Ministry of Education Youth and Sport | ក្រសួងអប់រំ យុវជន និង កីឡា |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoI | Ministry of the Interior | ក្រសួងមហាផ្ទៃ |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoWVA | Ministry of Women's and veteran's Affairs | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន |
| NIE | National Institute of Education | វិទ្យាស្ថានជាតិអប់រំ |
| MTEF | Medium Term Expenditure Framework | ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម |
| MTEP | Medium Term Expenditure Plan (for Education) | ផែនការចំណាយរយៈពេលមធ្យម (សំរាប់អប់រំ) |
| NCSC | National Council for Support for Communes | ក្រុមប្រឹក្សាជាតិសំរាប់គាំទ្រឃុំ |
| NFE | Non Formal Education | អប់រំក្រៅប្រព័ន្ធ |
| NEP | NGO Education Partnership | ភាពជាដៃគូអប់រំអង្គការក្រៅរដ្ឋាភិបាល |
| NGO | Non-Government Organization | អង្គការក្រៅរដ្ឋាភិបាល |
| NPAR | National Program for Administrative Reform | កម្មវិធីជាតិសំរាប់កំណែទំរង់រដ្ឋបាល |
| NPRS | National Poverty Reduction Strategy | យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ |
| NTB | National Training Board | ក្រុមប្រឹក្សាបណ្តុះបណ្តាលថ្នាក់ជាតិ |
| NTF | National Training Fund | កម្មវិធីមូលនិធិសំរាប់ការបណ្តុះបណ្តាលថ្នាក់ជាតិ |
| PAI | Public Administrative Institution | គ្រឹះស្ថានរដ្ឋបាលសាធារណៈ |
| PAP | Priority Action Program | កម្មវិធីសកម្មភាពជាអាទិភាព |
| PEEC | Public enterprise with economic characteristics | សហគ្រាសសាធារណៈ មានលក្ខណៈសេដ្ឋកិច្ច |
| PDH | Publishing and Distribution House | គ្រឹះស្ថានបោះពុម្ព និង ចែកផ្សាយ |
| PFM | Public Finance Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PNTR | Pupil / Non Teaching staff ratio | ផលធៀបសិស្ស - បុគ្គលិកមិនបង្រៀន |
| PRESET | Pre-service Teacher Training | ការបណ្តុះបណ្តាលគ្រូ |

| | | |
|---|---|---|
| PTR | Pupil Teacher Ratio | ផលធៀបសិស្ស-គ្រូ |
| PTC | Provincial Training Center | សាលាបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត |
| PTTC | Provincial Teacher Training College | សាលាគរុកោសល្យ និងវិក្រឹត្យការខេត្ត |
| RTTC | Regional Teacher Training College | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |
| ESDP | Education Sector Development Program | កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំ |
| TTD | Teacher Training Department | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| TTC | Teacher Training College | សាលាគរុកោសល្យ |
| TVET | Technical and Vocational Education Training | អប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ |
| US$ | United States Dollar | ប្រាក់ដុល្លាអាមេរិក |
| WTO | World Trade Organization | អង្គការពាណិជ្ជកម្មពិភពលោក |